# ក

# មាតិកា

## I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១. ព្រះរាជក្រឹត្យ

២៩-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៦២៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឩ ស៊ីនយ៉ាង** (WU HSIN YANG) ជនជាតិចិន សញ្ជាតិចិន កើតនៅ ទីក្រុងតៃប៉ិ សាធារណរដ្ឋចិន (តៃវ៉ាន់) ៥៩៤៤

២៩-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៦២៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ័ង ប៉ូសាង** (HUANG PO TSANG) ជនជាតិចិន សញ្ជាតិចិន កើតនៅ ទីក្រុងកៅស៊ុង សាធារណរដ្ឋចិន (តៃវ៉ាន់) ៥៩៤៥

២៩-៦-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៦១១/៦២៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ចាន់ ស៊ីវហុង** (CHAN HSIU HONG) ជនជាតិចិន សញ្ជាតិចិន កើតនៅ ទីក្រុងតៃជុង សាធារណរដ្ឋចិន (តៃវ៉ាន់) ៥៩៤៦

២០-៧-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៧១១/៦៨២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ីម យ៉ុងស៊ុប** (SIM YUNG SUB) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅ ទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ៥៩៤៧

២០-៧-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៧១១/៦៨៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីវ ស៊ុនលីន** (LIU XUNLIN) ជនជាតិចិន សញ្ជាតិចិន កើតនៅ ខេត្តហ៊ីណាន សាធារណរដ្ឋប្រជាមានិតចិន ៥៩៤៨

២១-៧-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៧១១/៦៨៧ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសពនាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២ រូប ៥៩៤៩

២១-៧-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៧១១/៦៨៨ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ដល់ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ២៤ រូប ៥៩៥០

២១-៧-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៧១១/៦៨៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ លោក **Kitahashi Kenji** អភិបាលក្រុង **Kitakyushu (Mayor of Kitakyuhu City)** ៥៩៥២

២១-៧-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៧១១/៦៩០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ចំនួន ១២ រូប ៥៩៥៣

២១-៧-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៧១១/៦៩១ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ និង សប្បុរសជន ចំនួន ៣៦ រូប ៥៩៥៤

២២-៧-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៧១១/៦៩២ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ ជូន ឯកឧត្តម ឆេត ឆន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ពី វរមន្ត្រី ថ្នាក់លេខ ៤ ទៅ ឧត្តមមន្ត្រី ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ៥៩៥៦

២៥-៧-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៧១១/៦៩៣ ស្ដីពី ការដាក់ឱ្យចូលនិវត្តន៍ ចំពោះចៅក្រម និង ព្រះរាជអាជ្ញា ចំនួន ០៩ រូប ៥៩៥៧

២៥-៧-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៧១១/៦៩៤ ស្ដីពី ការបានអនុញ្ញាតជូន ចៅក្រម និង ព្រះរាជអាជ្ញា ដែលដល់អាយុចូលនិវត្តន៍ ឱ្យនៅបន្តការងារ ចំនួន ១៩ រូប ៥៩៥៩

## II.រាជរដ្ឋាភិបាល

### ១.អនុក្រឹត្យ

២៥-៧-២០១១ -អនុក្រឹត្យលេខ ១៧២ អនក្រ.បក ស្ដីពី ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាង ស្រុកកំពង់លាវ និង ស្រុកពារាំង ខេត្តព្រៃវែង ៥៩៦១

២៥-៧-២០១១ -អនុក្រឹត្យលេខ ១៧៣ អនក្រ.បក ស្ដីពី ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាង ស្រុកដំណាក់ចង្អើរ និង ក្រុងកែប ខេត្តកែប ៥៩៦៤

២៥-៧-២០១១ -អនុក្រឹត្យលេខ ១៧៤ អនក្រ.បក ស្ដីពី ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាង សង្កាត់បាវិត និង សង្កាត់ច្រកម្ទេស នៃក្រុងបាវិត ខេត្តស្វាយរៀង ៥៩៦៧

២៩-៧-២០១១ -អនុក្រឹត្យលេខ ១៧៥ អនក្រ.បក ស្ដីពី ការបង្កើតនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈថ្នាក់ក្រោមជាតិ និង វិស្វកម្ម ជំនួសនាយកដ្ឋានសំណង់ផ្លូវអាកាស ៥៩៧០

២៦-៧-២០១១ -អនុក្រឹត្យលេខ ៨៦៥ អនក្រ.តត ស្ដីពី ការតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល ៥៩៧៥

២៦-៧-២០១១ -អនុក្រឹត្យលេខ ៨៦៦ អនក្រ.តត ស្ដីពី ការដាក់មន្ត្រីរាជការឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស និង បន្ថយថ្នាក់ ៥៩៨៣

២៦-៧-២០១១ -អនុក្រឹត្យលេខ ៨៦៧ អនក្រ.តត ស្ដីពី ការជូនមេដាយសុវត្ថារា ៥៩៨៥

២៦-៧-២០១១ -អនុក្រឹត្យលេខ ៨៦៨ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៥៩៨៦

២៦-៧-២០១១ -អនុក្រឹត្យលេខ ៨៦៩ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៥៩៨៨

២៦-៧-២០១១ -អនុក្រឹត្យលេខ ៨៧០ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៥៩៨៩

២៦-៧-២០១១ -អនុក្រឹត្យលេខ ៨៧១ អនក្រ.តត ស្ដីពី ការជូនមេដាយស្ថាបនាជាតិ ៥៩៩១

២៦-៧-២០១១ -អនុក្រឹត្យលេខ ៨៧២ អនក្រ.តត ស្ដីពី ការជូនមេដាយការងារ ៥៩៩៣

២៦-៧-២០១១ -អនុក្រឹត្យលេខ ៨៧៣ អនក្រ.តត ស្ដីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៥៩៩៥

២៦-៧-២០១១ -អនុក្រឹត្យលេខ ៨៧៤ អនក្រ.បក ស្តីពី ការជូនគ្រឿងឥស្សរិយយសសុវត្ថារា ៥៩៩៧
២៦-៧-២០១១ -អនុក្រឹត្យលេខ ៨៧៥ អនក្រ.បក ស្តីពី ការជូនមេដាយសហមេត្រី ៥៩៩៩
២៦-៧-២០១១ -អនុក្រឹត្យលេខ ៨៧៦ អនក្រ.បក ស្តីពី ការជូនមេដាយសុវត្ថារា ៦០០០
២៦-៧-២០១១ -អនុក្រឹត្យលេខ ៨៧៧ អនក្រ.បក ស្តីពី ការជូនមេដាយការងារ ៦០០២
២៧-៧-២០១១ -អនុក្រឹត្យលេខ ៨៧៨ អនក្រ.បក ស្តីពី ការលុបឈ្មោះមន្ត្រីរាជការ ៦០០៧
២៧-៧-២០១១ -អនុក្រឹត្យលេខ ៨៧៩ អនក្រ.បក ស្តីពី ការជូនមេដាយសហមេត្រី ៦០០៨

## ២. សេចក្តីសម្រេច

០៣-៨-២០១១ -សេចក្តីសម្រេចលេខ ៤៥ សសរ ស្តីពី ការបង្កើតអនុក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម ផ្នែករាជរដ្ឋាភិបាល ៦០១០

## III. ការិយាល័យបណ្តាក្រសួង

### ១. ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៨-៧-២០១១ -សារាចរណែនាំលេខ ០១០ សហវ ស្តីពី នីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០១២ ៦០១៣
២៥-៧-២០១១ -សារាចរណែនាំអនុវត្តលេខ ០១១ សហវ ស្តីពី ប្រកាសលេខ ៣៨៣ សហវ.អពដ.ប្រក ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ២០១១ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ៦០៣១

### ២. ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៦-៧-២០១១ -ប្រកាសលេខ ៥៩៨ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ិនធីណាស្យូណល់ ផេភ័រប្រូឌឹក ម៉េញ៉ូហ្វាក់ធរីង បង្កើតរោងចក្រ ផលិតកេសកាតុង ៦០៣៣
០៧-៧-២០១១ -ប្រកាសលេខ ៦១២ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊ីជីនចេន (ខេមបូឌា) បង្កើតរោងចក្រ ផលិតអំបោះ និង បន្ទះស្អិត (Adhesive tape) ៦០៣៧
០៧-៧-២០១១ -ប្រកាសលេខ ៦១៣ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ណាស៊ី អ៊ិនដាសស្រ្ទី បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៦០៤១

### ៣. ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

៣០-៨-២០១០ -លិខិតបញ្ជាក់លេខ ៤០០៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហោសេនបើគ អ៊ិនវេសមេន** ៦០៤៥
៣០-៨-២០១០ -លិខិតបញ្ជាក់លេខ ៤០០៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្រីន អ៊ែរ ខូ អិលធីឌី** ៦០៤៧
៣០-៨-២០១០ -លិខិតបញ្ជាក់លេខ ៤០១៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វី ជា អ៊ិនវេសមេន** ៦០៤៩

៣០-៨-២០១០ -លិខិតបញ្ជាក់លេខ ៤០១៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ម ខណ្ឌងី ខសរមេងិត អ៊ីមផត អិចផត** ៦០៥១
៣០-៨-២០១០ -លិខិតបញ្ជាក់លេខ ៤០១៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីអធីទី-ខមម្យូនីខេសិន ខូ អិលធីឌី** ៦០៥៣
៣០-៨-២០១០ -លិខិតបញ្ជាក់លេខ ៤០១៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្រាយ ផៅវ៉េរ ខូ អិលធីឌី** ៦០៥៥
៣០-៨-២០១០ -លិខិតបញ្ជាក់លេខ ៤០២១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេហ្វ.អិន.អិន ខនសាល់ធីង** ៦០៥៧

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៦៥៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ញាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១**៖ ផ្តល់សញ្ញាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **វូ ស៊ីនយ៉ាង** (WU HSIN YANG) ជនជាតិចិន សញ្ញាតិចិន កើតថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ១៩៧៨ នៅទីក្រុងតៃប៉ិ សាធារណរដ្ឋចិន (តៃវ៉ាន់) ។

**មាត្រា ២**៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣**. ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង ,ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១

៣រល.១១០៦.៦៣៩

លេខៈ ៥៩៦ ច.ល
បានថតចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី០៤ខែកក្កដាឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចាន់ថុល

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៦៧៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ហ័ង ប៉ូសាង** (HUANG PO TSANG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ១៥ ខែ សីហា ឆ្នាំ១៩៧៨ នៅទីក្រុងកៅស៊ុង សាធារណរដ្ឋចិន(តៃវ៉ាន់)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

 លេខៈ ...៩ ច.ល
ជូនដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ កក្កដា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

៣រល. ១១០៦. ៦៣៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១*

**យុន ជិនអេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១១/៦២៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យលព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យលសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ចាន់ ស៊ីវហុង** (CHAN HSIU HONG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៦១ នៅទីក្រុងតៃជុង សាធារណរដ្ឋចិន (តៃវ៉ាន់) ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១

ចរល. ១១០៦. ៦៤០

លេខៈ ៥៩៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនអេន

# ព្រះរាជក្រឹត្យ

នស/រកត/០៧១១/៦៥២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្ននខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ស៊ីម យ៉ុងស៊ុប** (SIM YUNG SUB) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៦៩ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១១០៧. ៦៩៤

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១១

លេខ: ៧៥៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១១
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**យ៉ុន ជិនអេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១១/៦៧៣

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **លីវ ស៊ិនលីន** (LIU XUNLIN) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៧៣ នៅខេត្តហឺណាន សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣វល. ១១០៧. ៦៩៩

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១១

លេខៈ ៦៥៥ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជីនអេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១១/៦៤៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ជូនសពនាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ

**ក. ដំឡើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ទោ :**

- ឧត្តមសេនីយ៍ត្រី **គីម សាឃុន** អត្តលេខ ០០៨៥២៥

**ខ. ដំឡើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី :**

- វរសេនីយ៍ឯក **ឌុយ ប៊ុនរ៉េត** អត្តលេខ ០០១១៧០

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

**លេខ: ៦៧៥ ច.ល**
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ឃុន ជិនកេន**

ពរល. ១១០៧.៧០៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១

# ព្រះរាជក្រឹត្យ

នស/រកត/០៧១១/៦៤៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានដំឡើងឋានន្តរសក្តិ ដល់ នាយទាហាន ជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

**ក.ដំឡើងឋានន្តរសក្តិ ថ្នាក់ ឧត្តមនាវីទោ :**

១-ឧត្តមនាវីត្រី **ហាន ចាំ** អត្តលេខ ០០២៥៣១
២-ឧត្តមនាវីត្រី **យស សម្បត្តិ** អត្តលេខ ០០១១១៦
៣-ឧត្តមនាវីត្រី **ជ័យ ណារី** អត្តលេខ ០១៧៦៩១
៤-ឧត្តមនាវីត្រី **យឹម គឹមនី** អត្តលេខ ០០២៥២៥
៥-ឧត្តមនាវីត្រី **យឹម អក្ខរា** អត្តលេខ ០០២៥១៦
៦-ឧត្តមនាវីត្រី **ទ្រឹក ប៊ុនធឿន** អត្តលេខ ០០២៥១៣
៧-ឧត្តមនាវីត្រី **អ៊ិន ប៊ុនលី** អត្តលេខ ០០១១០៣
៨-ឧត្តមនាវីត្រី **នេត្រ ស៊ីប្រូ** អត្តលេខ ០០១១១០
៩-ឧត្តមនាវីត្រី **ឃុន ធុទ្ធី** អត្តលេខ ០០១១១១
១០-ឧត្តមនាវីត្រី **ខឹម សិទ្ធី** អត្តលេខ ០០១១០៧
១១-ឧត្តមនាវីត្រី **កែវ សារ៉េត** អត្តលេខ ០០២៥០៦



១២-ឧត្តមនាវីត្រី **សំ សុខា** អត្តលេខ ០០២៥០៧

១៣-ឧត្តមនាវីត្រី **ម៉ី ឌីណា** អត្តលេខ ០១៥១០៦

១៤-ឧត្តមនាវីត្រី **ហ៊ុំ ពុធដារ៉ា** អត្តលេខ ០០១១១៣

១៥-ឧត្តមនាវីត្រី **រស់ ខាសនា** អត្តលេខ ០១០២៩៨

១៦-ឧត្តមនាវីត្រី **ម៉ុំ សំ** អត្តលេខ ០០២៨១៥

**ខ-ឡើងឋានន្តរសក្តិ ថ្នាក់ ឧត្តមនាវីត្រី :**

១-វរនាវីឯក **សេង ណារិន** អត្តលេខ ០១០២៨៣

២-វរនាវីឯក **គីម សាឌុង** អត្តលេខ ០១០៣០៦

៣-វរនាវីឯក **ខូច លីន** អត្តលេខ ០១០៥៦៦

៤-វរនាវីឯក **លឹម សារឿន** អត្តលេខ ០១៥០៨៤

៥-វរនាវីឯក **ចាប់ សុវណ្ណារិទ្ធ** អត្តលេខ ០០២៥០២

៦-វរនាវីឯក **ញឹល ស៊ីន** អត្តលេខ ០១០២៩៣

៧-វរនាវីឯក **ឈៀង សុខា** អត្តលេខ ០០២៥១០

៨-វរនាវីឯក **សួន ម៉ីនផល** អត្តលេខ ០១៥០២៧

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រឈ. ១១០៧. ៧០៤

ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១

លេខៈ ៦៧៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី២៨ខែកក្កដាឆ្នាំ២០១១
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១១/៦៩៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

**គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍**

ចំពោះ

**លោក Kitahashi Kenji**

អភិបាលក្រុង Kitakyushu ( Mayor of Kitakyushu City ) ដែលមានស្នាដៃនិងគុណបំណាច់ខ្ពស់ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ
រវាងរដ្ឋាករទឹកក្រុងគីតាក្យូស៊ូ (Kitakyushu) នៃប្រទេសជប៉ុនជាមួយរដ្ឋាករទឹកស្វយ័ត ក្រុងភ្នំពេញ លើវិស័យទឹកស្អាត

៣រល. ១១០៧. ៧០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១

លេខៈ ៦៥៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី២៧ខែកក្កដា ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៧១១/៦៩០

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ចំនួន ១២ រូប ចំណុះយោធភូមិភាគពិសេស , យោធភូមិភាគទី ៤ និង យោធភូមិភាគទី ៥ មានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

១- វរសេនីយ៍ទោ **កែប អនុជ** ០២១៦៥២
២- វរសេនីយ៍ត្រី **យូ សុខ** ០១១៤៥៩
៣- អនុសេនីយ៍ឯក **ជួប សម្បត្តិ** ០១៩៧៣៣

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :**

១- វរសេនីយ៍ត្រី **រស់ សារិទ្ធ** ០១៥៧៨២
២- អនុសេនីយ៍ទោ **ភាច សុវណ្ណៈ** ០៣១៥២៩

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :**

១- វរសេនីយ៍ទោ **មាស តារា** ០១០៣៥៦
២- វរសេនីយ៍ត្រី **ពិន ចាន់ថុល** ១១២៨៩៧
៣- វរសេនីយ៍ត្រី **សែម បុប្ផា** ០១២៨៩២
៤- វរសេនីយ៍ត្រី **លឹម ចាន់លី** ០២៣៨៨២
៥- វរសេនិយ៍ត្រី **សុខ សុផល** ១៩១៨៣១
៦- អនុសេនីយ៍ឯក **ឆេព សុមនា** ០៥៦៤៧២
៧- អនុសេនីយ៍ឯក **គក់ ណាគ** ០៨៨៦៩៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៦៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

**យុន ជិនកេន**

ពរណ. ១១០៧. ៧០៦

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១១

# ព្រះរាជក្រឹត្យ

នស / រកត / ០៧១១ / ៦៩៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

មន្ត្រីរាជការ និងសប្បុរសជន ចំនួន៣០រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ

**នូវ**

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តម ស្រាក់ ស៊ីហាក់
២-ឧកញ៉ា ឡាច កាង
៣-លោក សំ សំអាត
៤-ឧត្តមសេនីយ៍ត្រី ម៉ាង និន អត្តលេខ០០០៣០៥
៥-លោក ខេង គេង
៦-លោក ចោង សុខារត្ន
៧-លោក សេង សុខុម

**ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តម ស៊ីវិន្ទ គុំ
២-លោក កៅ ចន

**គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-លោក សន កុសល
២-លោក សុខ ផន

**ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១-ឯកឧត្តម ឡុង ពៅស្រាថ្វា
២-ឧត្តមសេនីយ៍ទោ រស់ ឆៀត អត្តលេខ ០០០៩៥៧
៣-វរសេនីយ៍ឯក មោង ប៊ុនធី អត្តលេខ ០១២០៦៣
៤-លោក ឆេត ចិសិដ្ឋ
៥-លោក ឈេង ឆឿន
៦-អនុសេនីយ៍ឯក សំ សាភាន អត្តលេខ ០៣៦១២៤
៧-លោក ជា ឆាង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១-លោក ឃួត ផុន
២-លោកស្រី ឈឹម គីមឈី
៣-លោកស្រី សេង ស៊ីណាត
៤-លោក តុប ពេញ
៥-លោកស្រី ហ៊ី ឡាន់

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១-វរសេនីយ៍ឯក ខៀវ សំណាង អត្តលេខ ០១២៥៣៨
២-លោក ស៊ុត ចាន់ថន
៣-លោក សេរី សម្បត្តិ
៤-លោក ម៉ៃ ចន្ថាសឿង
៥-លោក ឌុត ឈីម្ហួយ
៦-លោក គង់ ចិន្តានៈ
៧-លោក ឌួច ធឿន

ឃ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១-លោក ជា ណារឿន
២-លោក ចេង រ៉េត
៣-លោក នោម ប៊ុនធឿន
៤-លោក សែន សុខុម
៥-វរសេនីយ៍ទោ កែន ចន្ធះ អត្តលេខ ០២៥៨៨៤
៦-វរនាវីទោ ស្វាយ សុទ្ធី អត្តលេខ ០១៥០៦២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩ល. ១១០៧. ៧០៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ២០១១

លេខ: ៦៧៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៧១១/៦៩២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ត្រូវបានដំឡើងឋានន្តរស័ក្តិជូនឯកឧត្តម **ឆេង ឆន** អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ពី វរមន្ត្រី ថ្នាក់លេខ ៤ ទៅ ឧត្តមមន្ត្រី ថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា ២:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

ពរល. ១១០៧. ៧០៩

លេខ ៦៥៨ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១១

**ឃួន ឋិនគេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១១/៦៩៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩នស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៥/៩០៣ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការដាក់ឲ្យចូលនិវត្តន៍ចៅក្រម និងព្រះរាជអាជ្ញា ដែលមានអាយុចាប់ពី ៦០ឆ្នាំឡើង
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១១

## ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានដាក់ឲ្យចូលនិវត្តន៍ ចំពោះចៅក្រម និងព្រះរាជអាជ្ញា ដូចមានរាយនាមខាងក្រោម:

| | |
|---|---|
| ១ - ឯកឧត្តម **ឆ៉ាន់ ផាន់** | ចៅក្រម |
| ២ - លោក **តូច សារឿន** | ប្រធានសាលាដំបូងខេត្តក្រចេះ |
| ៣ - ឯកឧត្តម **អ៊ិត រ៉ាឌី** | ចៅក្រមក្រសួងយុត្តិធម៌ ដោយរក្សាមុខតំណែងអនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ នៅដដែល |
| ៤ - លោក **ជ័យ សុវណ្ណ** | ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ |
| ៥ - លោកស្រី **គង់ គួយ** | អនុប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ |
| - លោក **ឡូ ទើង** | អនុប្រធានសាលាដំបូងខេត្តមណ្ឌលគិរី |
| លោក **ផន់ សាម៉ុន** | អនុប្រធានសាលាដំបូងខេត្តស្វាយរៀង |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៨ - លោក **ជា ឆល់** ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍

៩ - លោក **ថោ សារ៉ែន** អនុប្រធានសាលាដំបូងខេត្តរតនគិរី ចាប់ពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១១ ។

**មាត្រា២:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣:** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*នស/រកត.១១០៧.៧០៩*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១១*

**លេខ: ៦៦៥ ច.ល**
**ដើម្បីចម្លងចែកជូន**
រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១១/៦៩៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩នស.៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៥/៩០៣ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការដាក់ឲ្យចូលនិវត្តន៍ចៅក្រម និងព្រះរាជអាជ្ញា ដែលមានអាយុចាប់ពី ៦០ឆ្នាំឡើង
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១១

## ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានអនុញ្ញាតជូនចៅក្រម និងព្រះរាជអាជ្ញា ដែលដល់អាយុចូលនិវត្តន៍ ឲ្យនៅបន្តការងារ ដូចមានរាយនាមខាងក្រោម:

| | | |
|---|---|---|
| ១ - ឯកឧត្តម | **ឌិត មុន្ទី** | ប្រធានតុលាការកំពូល |
| ២ - ឯកឧត្តម | **ឃឹម ប៉ុណ្ណ** | អនុប្រធានតុលាការកំពូល |
| ៣ - លោក | **ប្រាក់ គឹមសាន** | ចៅក្រមតុលាការកំពូល |
| ៤ - លោក | **យស់ សុខឿន** | ចៅក្រមតុលាការកំពូល |
| ៥ - លោក | **ឌី ណោង** | ចៅក្រមតុលាការកំពូល |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ៦ - ឯកឧត្តម | **ជួន ស៊ីនឡេង** | អនុប្រធានសាលាឧទ្ធរណ៍ |
| ៧ - លោក | **ស៊ំរិទ្ធិ សុផល** | ចៅក្រមសាលាឧទ្ធរណ៍ |
| ៨ - លោក | **អ៊ុំ សារិទ្ធ** | ចៅក្រមសាលាឧទ្ធរណ៍ |
| ៩ - លោក | **អ៊ីង សារុន** | ចៅក្រមសាលាឧទ្ធរណ៍ |
| ១០ - លោក | **ធិត សុទ្ធី** | ប្រធានសាលាដំបូងខេត្តកំពង់ចាម |
| ១១ - លោក | **ថោង អុល** | ប្រធានសាលាដំបូងខេត្តពោធិសាត់ |
| ១២ - លោក | **ខ្លូត ពេជ្រ** | ប្រធានសាលាដំបូងខេត្តកំពង់ស្ពឺ |
| ១៣ - ឯកឧត្តម | **ជីវ កេង** | ប្រធានសាលាដំបូងរាជធានីភ្នំពេញ |
| ១៤ - លោក | **ឌុច ចន្ថា** | ចៅក្រមសាលាដំបូងខេត្តពោធិសាត់ |
| ១៥ - លោក | **ម៉ក់ គាង** | ចៅក្រមសាលាដំបូងខេត្តក្រចេះ |
| ១៦ - លោកស្រី | **បេ គីមយាង** | ចៅក្រមសាលាដំបូងខេត្តស្ទឹងត្រែង |
| ១៧ - លោក | **មួង សារិន** | ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ចាម |
| ១៨ - ឯកឧត្តម | **អ៊ឹក ឆួច** | នាយកសាលាភូមិន្ទអាជ្ញាសាលា |
| ១៩ - ឯកឧត្តម | **គាន់ ឈឿន** | នាយកសាលាភូមិន្ទក្រឡាបញ្ជី |

**មាត្រា២:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣:** ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត. ០៧១១.៧២០

*ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១១*

**លេខ: ៦៦៤ ច.ល**
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១១
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១៣២...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងស្រុកកំពង់លាវ និងស្រុកពារាំង ខេត្តព្រៃវែង

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងស្រុកកំពង់លាវ និងស្រុកពារាំង ខេត្តព្រៃវែង ដោយកាត់យកឃុំចំនួន ០២ នៃស្រុកពារាំងគឺ ឃុំព្រែកតាសរ និងឃុំកំពង់ឫស្សី មកបញ្ចូលក្នុងស្រុកកំពង់លាវ ។

ផ្អែកតាមការកែសម្រួលនេះ ព្រំប្រទល់រដ្ឋបាលរវាងស្រុកកំពង់លាវ និងស្រុកពារាំង ខេត្តព្រៃវែង ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានផ្លាស់ប្តូរទីតាំងសាលាស្រុកកំពង់លាវដែលស្ថិតនៅក្នុងឃុំតាកោ មកនៅទីតាំងថ្មីស្ថិតនៅក្នុងឃុំពោធិ៍រៀង ។

**មាត្រា ៣.-**

ត្រូវបានប្តូរឈ្មោះស្រុកកំពង់លាវ ខេត្តព្រៃវែង មកជាស្រុកពោធិ៍រៀង ខេត្តព្រៃវែង ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្តព្រៃវែង គណៈអភិបាលខេត្តព្រៃវែង ក្រុមប្រឹក្សាស្រុកពោធិ៍រៀង គណៈអភិបាលស្រុកពោធិ៍រៀង ក្រុមប្រឹក្សាស្រុកពារាំង គណៈអភិបាលស្រុកពារាំង ក្រុមប្រឹក្សាឃុំពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ


មាត្រដ្ឋាន: 1:90,000

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ១៧៣ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងស្រុកដំណាក់ចង្អើរ និងក្រុងកែប ខេត្តកែប

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងស្រុកដំណាក់ចង្អើរ និងក្រុងកែប ខេត្តកែប ដោយកាត់យកឃុំអូរក្រសារ នៃស្រុកដំណាក់ចង្អើរ មកបញ្ចូលក្នុងក្រុងកែប និងកាត់យកដីមួយផ្នែករបស់ភូមិដំណាក់ចង្អើរ នៃសង្កាត់ព្រៃធំ ក្រុងកែប មកបញ្ចូលក្នុងភូមិភ្នំលាវ នៃឃុំពងទឹក ស្រុកដំណាក់ចង្អើរ ។

ផ្អែកតាមការកែសម្រួលនេះ ព្រំប្រទល់រដ្ឋបាលរវាងស្រុកដំណាក់ចង្អើរ និងក្រុងកែប ត្រូវបានកំណត់ដូចមាន ក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្តូរឃុំអូរក្រសារ ទៅជាសង្កាត់អូរក្រសារ នៃក្រុងកែប ខេត្តកែប ។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្តកែប គណៈអភិបាលខេត្តកែប ក្រុមប្រឹក្សាក្រុងកែប គណៈអភិបាលក្រុងកែប ក្រុមប្រឹក្សាស្រុកដំណាក់ចង្អើរ គណៈអភិបាលស្រុកដំណាក់ចង្អើរ ក្រុមប្រឹក្សាសង្កាត់អូរក្រសារ ក្រុមប្រឹក្សាសង្កាត់ព្រៃធំ និងក្រុមប្រឹក្សាឃុំពងទឹក ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ផែនទីកែសម្រួលព្រំប្រទល់រដ្ឋបាល
រវាងក្រុងកែប និងស្រុកដំណាក់ចង្អើរ ខេត្តកែប
ក្រុងកែប
ស្រុកដំណាក់ចង្អើរ
ស្រុកទឹកឈូ ខេត្តកំពត
ស្រុកកំពង់ត្រាច ខេត្តកំពត
N
កំណត់សំគាល់
Legend

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៣៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងសង្កាត់បាវិត និងសង្កាត់ច្រកម្ទេស នៃក្រុងបាវិត ខេត្តស្វាយរៀង

### រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងសង្កាត់បាវិត និងសង្កាត់ច្រកម្ទេស នៃក្រុងបាវិត ខេត្តស្វាយរៀង ដោយកាត់យកផ្ទៃដីមួយផ្នែកពីភូមិព្រៃផ្តៅ នៃសង្កាត់ច្រកម្ទេស មកបញ្ចូលក្នុងភូមិតាពៅ នៃសង្កាត់បាវិត។

ផ្អែកតាមការកែសម្រួលនេះ ព្រំប្រទល់រដ្ឋបាលរវាងសង្កាត់បាវិត និងសង្កាត់ច្រកម្ទេស ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្តស្វាយរៀង គណៈអភិបាលខេត្តស្វាយរៀង ក្រុមប្រឹក្សាក្រុងបាវិត គណៈអភិបាលក្រុងបាវិត ក្រុមប្រឹក្សាសង្កាត់បាវិត និងក្រុមប្រឹក្សាសង្កាត់ច្រកម្ទេស ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ




| [illegible] | | |
|---|---|---|
| [illegible] GPSmap 60CSx | | |
| Projection UTM, Zone 48N, Datum WGS 84 | | |
| Point ID | Easting | Northing |
| 1 | 620067.236 | 1222203.979 |
| 2 | 620063.804 | 1223001.867 |
| 3 | 620187.937 | 1223000.850 |
| 4 | 620176.403 | 1223796.357 |
| 5 | 620147.285 | 1223636.407 |
| 6 | 620111.906 | 1223976.617 |
| 7 | 620056.733 | 1224057.433 |
| 8 | 620005.652 | 1224316.807 |
| 9 | 620153.091 | 1224460.062 |
| 10 | 620761.867 | 1224118.241 |
| 11 | 620704.621 | 1223334.584 |
| 12 | 620667.104 | 1223125.582 |
| 13 | 620624.226 | 1222976.496 |
| 14 | 620618.888 | 1222862.945 |
| 15 | 620683.183 | 1222611.047 |
| 16 | 620774.296 | 1222368.947 |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៥ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈថ្នាក់ក្រោមជាតិ និងវិស្វកម្ម ជំនួសនាយកដ្ឋានសំណង់ផ្លូវអាកាស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

## សម្រេច

**មាត្រា ១.**

ត្រូវបានលុបនាយកដ្ឋានសំណង់ផ្លូវអាកាសចេញពីរចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋានសាធារណការនិងសំណង់ នៃក្រសួងសាធារណការនិងដឹកជញ្ជូន។

ត្រូវបានបង្កើតនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈថ្នាក់ក្រោមជាតិនិងវិស្វកម្ម ឱ្យស្ថិតនៅក្រោមអគ្គនាយកដ្ឋានសាធារណការនិងសំណង់នៃក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា ២.**

នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈថ្នាក់ក្រោមជាតិនិងវិស្វកម្ម មានតួនាទីនិងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងការងារហេដ្ឋារចនាសម្ព័ន្ធសាធារណៈថ្នាក់ក្រោមជាតិដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- គ្រប់គ្រងការងារវិស្វកម្ម
- សម្របសម្រួលការងារផ្លូវថ្នល់ជាមួយនឹងក្រសួង ស្ថាប័ន និងអង្គភាពគ្រប់គ្រងផ្លូវថ្នល់នានា
- រៀបចំនិងលើកគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈក្រោមដីដែលពាក់ព័ន្ធនឹងប្រព័ន្ធចម្រោះទឹកកខ្វក់និងផ្លូវក្នុងដី និងហេដ្ឋារចនាសម្ព័ន្ធលើដី ដូចជា ផ្លូវថ្នល់ ផ្លូវរំលង និងប្រព័ន្ធការពារទឹកជំនន់ក្នុងរាជធានី ខេត្ត ជាដើម
- គ្រប់គ្រងគម្រោងទីចំណត ទីសំចតយានយន្ត សួនច្បារ និងរុក្ខកម្ម ក្នុងរាជធានី ខេត្ត
- រៀបចំបទដ្ឋានបច្ចេកទេសសម្រាប់គ្រប់គ្រងការងារហេដ្ឋារចនាសម្ព័ន្ធសាធារណៈថ្នាក់ក្រោមជាតិនិងវិស្វកម្ម
- ធ្វើទំនាក់ទំនងនិងសហការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីធ្វើបច្ចុប្បន្នកម្មទិន្នន័យបណ្តាញផ្លូវថ្នល់
- ធ្វើរបាយការណ៍ការងារប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ
- បំពេញភារកិច្ចផ្សេងទៀតដែលក្រសួងប្រគល់ជូន។

នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈថ្នាក់ក្រោមជាតិនិងវិស្វកម្មត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។

**មាត្រា ៣.**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈថ្នាក់ក្រោមជាតិនិងវិស្វកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា ៤.**

មន្ត្រីដែលកំពុងបម្រើការងារនៅនាយកដ្ឋានសំណង់ផ្លូវអាកាសត្រូវផ្ទេរឱ្យទៅបម្រើការងារនៅនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈថ្នាក់ក្រោមជាតិនិងវិស្វកម្មវិញ។

**មាត្រា ៥.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដ ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៦*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# សន្ធានុក្រម

## របស់អនុក្រឹត្យលេខ ១៧៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០១១ ស្តីពីការបង្កើតនាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាធារណៈថ្នាក់ក្រោមជាតិ និងវិស្វកម្ម ជំនួសនាយកដ្ឋានសំណង់ផ្លូវអាកាស

**ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ:** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដោយរួមបញ្ចូលទាំងបរិក្ខារផ្លូវថ្នល់ សំណង់សិល្បការ្យ ប្រព័ន្ធការពារទឹកជំនន់ និងរាល់បរិក្ខារចាំបាច់ផ្សេងទៀតនៅលើផ្លូវថ្នល់ដែលបម្រើឲ្យបណ្តាញផ្លូវថ្នល់ និងសុវត្ថិភាពផ្លូវថ្នល់។

**បរិក្ខារផ្លូវថ្នល់:** សំដៅដល់ទីចំណត ទីសំចត ប្រព័ន្ធបង្ហូរទឹក ភ្លើងសញ្ញា សញ្ញាកំណត់ល្បឿន សញ្ញាបង្ហាញផ្លូវ ចន្លោះគម្លាត គំនូសសញ្ញាបែងចែកផ្លូវ ថ្មចិញ្ចើមផ្លូវ ជញ្ជាំងរបងការពារ បង្គោលគីឡូម៉ែត្រ និងបរិក្ខារផ្សេងទៀតនៅតាមបណ្តាញផ្លូវថ្នល់។

**បរិក្ខារសម្រួលការបង្ហូរទឹក:** សំដៅដល់ប្រឡាយ ស្នាមភ្លោះ អាងស្តុកទឹក ស្ថានីយចម្រោះទឹកកខ្វក់ ទីជម្រាល ឬចំណោត ។ល។ ដែលបានរៀបចំនៅតាមបណ្តាញផ្លូវថ្នល់សម្រាប់ការពារផ្លូវថ្នល់ បរិក្ខារផ្លូវថ្នល់ សុវត្ថិភាព ចរាចរណ៍ ការជួសជុល និងថែទាំផ្លូវថ្នល់។ វិជ្ជមាត្រនៃបរិក្ខារសម្រួលការបង្ហូរទឹក មានលទ្ធភាពគ្រប់គ្រាន់ សម្រាប់រយៈពេល និងប្រពលភាពនៃទឹកភ្លៀងធ្លាក់ចុះ និងបំពេញលក្ខខណ្ឌស្ថានភាពផ្លូវថ្នល់។

**សំណង់សិល្បការ្យ:** សំដៅដល់ស្ពាន លូ ផ្លូវរំលង ផ្លូវក្នុងដី ប្រព័ន្ធបង្ហូរទឹក អាងស្តុកទឹកបម្រើឲ្យផ្លូវថ្នល់ និងសំណង់រូបវន្តផ្សេងទៀតដែលផ្តល់នូវសុវត្ថិភាព ប្រសិទ្ធភាព និងស្ថេរភាពនៃផ្លូវថ្នល់។

**ផ្លូវទីក្រុង:** សំដៅដល់ផ្លូវដែលស្ថិតនៅក្នុងបរិវេណភូមិសាស្ត្ររដ្ឋបាលរាជធានី ខេត្ត ដោយរួមបញ្ចូលទាំងចិញ្ចើមផ្លូវនិងផ្លូវសម្រាប់មនុស្សដើរ។

**ផ្លូវសម្រាប់ដើរ:** សំដៅដល់ផ្នែកមួយនៃផ្លូវដែលធ្វើ ឬរៀបចំឡើងសម្រាប់ឲ្យថ្មើរជើងធ្វើដំណើរប្រកបដោយសុវត្ថិភាព។

**ទីចំណតយានយន្ត:** សំដៅដល់ទីកន្លែងឈប់យានជំនិះនៅស្ងៀមលើថ្នល់ផ្លូវ ឬកន្លែងកំណត់ណាមួយសម្រាប់រយៈពេលឆាប់បំផុត ដើម្បីឲ្យថ្មើរជើង ឬយានជំនិះដទៃទៀត ឆ្លងកាត់ ឬដើម្បីអែបខាងដាក់ទំនិញ ឬអ្នកដំណើរឡើងចុះ ហើយអ្នកបើកបរស្ថិតនៅជាប់នឹងចង្កូត ឬក្បែរយានជំនិះខ្លួន ។

**ទីសំចតយានយន្ត:** សំដៅដល់ទីកន្លែងទុកឲ្យយានជំនិះឈប់នៅស្ងៀមក្នុងរយៈពេលយូរ ឬឆាប់ដែលអ្នកបើកបរអាចរង់ចាំ ឬដើរចោលយានជំនិះខ្លួនបាន។

**បរិវេណសំចត:** សំដៅដល់ទីកន្លែងសាធារណៈដែលប្រើប្រាស់សម្រាប់យានជំនិះចត ប្រកបដោយភាពងាយស្រួល និងមានសុវត្ថិភាព មានច្រកចេញចូលក្នុងភាពបន្ទាន់ ទីកន្លែងឈប់សម្រាក និងទីកន្លែងប្រហាក់ប្រហែលផ្សេងទៀត។

**គម្រោងសាងសង់ផ្លូវថ្នល់:** សំដៅដល់គម្រោងទាំងឡាយដែលរៀបចំដោយស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងផ្លូវថ្នល់។

១០-ពលបាលទោ **សេក ឌីណា** អត្តលេខ ១៩៨ ៨៧២ ជាងផ្សារ ការិយាល័យសំភារៈ នាយកដ្ឋានវិស្វកម្ម

១១-ពលបាលទោ **អ៊ឹល ម៉ុនណារត** អត្តលេខ ១៩៨ ៨៦៩ ជំនួយការលេខាធិការដ្ឋាន នាយកដ្ឋានវិស្វកម្ម

១២-ពលបាលទោ **ធិត្យ សុផល** អត្តលេខ ១៩៨ ៧៨១ បើកបររថយន្ត កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

១៣-ពលបាលទោ **ស៊ូ សុធា** អត្តលេខ ១៩៨ ៨១១ បើកបររថយន្ត កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

១៤-ពលបាលទោ **ចៀម ចាន់** អត្តលេខ ១៩៨ ៨២៥ បើកបរគ្រឿងចក្រ កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

១៥-ពលបាលទោ **គុល វណ្ណា** អត្តលេខ ១៩៨ ៨៣៩ បើកបររថយន្ត កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

១៦-ពលបាលទោ **ប៉េង ចន្ថា** អត្តលេខ ១៩៨ ៧៦៥ បើកបររថយន្ត កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

១៧-ពលបាលត្រី **ផល ម៉ាន់ណោត** អត្តលេខ ១៩៨ ៨៧៧ បើកបររថយន្ត កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

១៨-ពលទោ **ហ៊ឹម សុភី** អត្តលេខ ២៤៤ ៧៦៣ ជាងម៉ាស៊ីន ការិយាល័យគ្រប់គ្រង នាយកដ្ឋានវិស្វកម្ម

១៩-ពលទោ **ជូ សុនី** អត្តលេខ ២៤៤ ៧៦៤ ជាងម៉ូទ័រ ការិយាល័យគ្រប់គ្រង នាយកដ្ឋានវិស្វកម្ម

២០-ពលទោ **ម៉ីន លួន** អត្តលេខ ២៤៤ ៧៤៦ បើកបររថយន្ត កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

២១-ពលទោ **ភី រ៉ាស៊ី** អត្តលេខ ២៤៤៧៣៧ បើកបរគ្រឿងចក្រ កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម/

២២-ពលទោ **ភឿ ភូរិទ្ធី** អត្តលេខ ២៥៨ ៧១៨ បើកបរគ្រឿងចក្រ កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

**គ-មេដាយសំរិទ្ធការងារ**

១-ពលបាលឯក **វ៉ាន់ គីម** អត្តលេខ ១៩៨ ៧៨៦ បើកបរគ្រឿងចក្រ កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

២-ពលទោ **គ្រៀល ថាន** អត្តលេខ ២២៥ ៧៨៨ បើកបររថយន្ត កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

៣-ពលទោ **ចាន់ រិទ្ធី** អត្តលេខ ២២៥ ៧២២ បើកបររថយន្ត កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

៤-ពលទោ **ប៉ុក ស៊ីថាន** អត្តលេខ ២២៥ ៧២៥ បើកបររថយន្ត កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

៥-ពលទោ **សន វណ្ណារ័ត្ន** អត្តលេខ ២២៥ ៧១៦ កុំព្យូទ័រ នាយកដ្ឋានវិស្វកម្ម

៦-ពលទោ **ភី រិទ្ធី** អត្តលេខ ២៥៨ ៧៣៨ បើកបររថយន្ត កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

៧-ពលទោ **សាត សុភក្តិ** អត្តលេខ ២៥៨ ៧៥៥ បើកបររថយន្ត កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

៨-ពលទោ **ទូច នឿន** អត្តលេខ ២៥៨ ៧១៧ ជាងជួសជុលរថយន្ត -គ្រឿងចក្រ កងគ្រឿងចក្រលេខ១៧៨ នាយកដ្ឋានវិស្វកម្ម

៩-ពលទោ **ម៉ុន ស៊ាងហ៊ត់** អត្តលេខ ២២៥ ៧៨១ បើកបររថយន្ត កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

១០-ពលទោ **គុល ចាន់ដាមុធ** អត្តលេខ ២៥៨ ៧៣៩ ជាងចាក់ល្វ កងគ្រឿងចក្រ នាយកដ្ឋានវិស្វកម្ម

១១-ពលទោ **ម៉េង តារ៉ា** អត្តលេខ ២២៥ ៧៨២ បើកបររថយន្ត កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

១២-ពលទោ **អ៊ូ សៅរ៉ូវ៉ា** អត្តលេខ ២២៥ ៧១៥ បើកបររថយន្ត កងគ្រឿងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

១៣-ពលទោ **មាន ច័ន្ទដារុធ** អត្តលេខ ២២៨ ៧១៥ បើកបររថយន្ត កងគ្រៀងចក្រ លេខ១៧៨ នាយកដ្ឋានវិស្វកម្ម

១៤-លោក **ស៊ុ ស្រស់** ជំនួយការគ្រៀងចក្រ

១៥-លោក **ចឺន សុរិយា** ជំនួយការគ្រៀងចក្រ

១៦-លោក **ទេព ពិសី** ជំនួយការ ការដ្ឋាន

១៧-លោកស្រី **កែវ ផារី** ចុងភៅ

**មាត្រា២ . -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
  ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៣៧៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការលុបឈ្មោះមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១ :** ត្រូវបានលុបឈ្មោះលោក **អ៊ុក ចន** រមន្ត្រីថ្នាក់លេខ ៥ ចេញពីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១ ដោយមូលហេតុមរណភាព។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៧៩ . អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ .-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ជូនសប្បុរសជនបរទេស ចំនួន ០៤ រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការ និងបានជួយកសាងមជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការ ៣១៧ គូលេនសៀមរាប ដូចមានរាយនាមខាងក្រោម ÷

**ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ**

-លោក **ង៉ូ ម៉ាញ់ ហ៊ុង** NGO MANH HUNG នាយកក្រុមហ៊ុន Metfone

**ខ-មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ**

១-លោក **តូប៊ៀស ស្តុក វែល** TOBIAS STOCKWELL ប្រធានក្រុមប្រឹក្សាភិបាលអង្គការ C.T.O មនុស្សនិង ធម្មជាតិ

២-លោក **ធំម៉ាស់ ហូលដូ ហាន់សិន** THOMAS HOLDO HANSEN នាយកក្រុមហ៊ុន វើលហ្វតែលលីង

៣-អ្នកស្រី **នីសាន់ ដេវី** NISANDAVY ប្រធានការិយាល័យក្រុមហ៊ុន
រើលហ្វតែលលីង

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៥. សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតអនុក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម ផ្នែករាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ១៤៩ អនក្រ.បក ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ២៧ សសរ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មាធិការ អនុគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន និងក្រុមការងារតាមវិស័យសម្រាប់ពិភាក្សាជាមួយផ្នែកឯកជន
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ២១ សសរ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មការជំរុញការនាំចេញកសិផល និងសេចក្តីសម្រេចបន្ថែមសមាសភាពលេខ៣៥ សសរ ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០០៩
- យោងសេចក្តីជូនដំណឹងលេខ ៥៤៩ សជណ.សរ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ស្តីពីលទ្ធផលនៃវេទិការាជរដ្ឋាភិបាល-

ផ្នែកឯកជនលើកទី១៥ នាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០

- យោងកិច្ចប្រជុំផ្សព្វផ្សាយឯកសារគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ នាថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០ នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងស្មារតីនៃកិច្ចប្រជុំរវាងគណៈកម្មាធិការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន ជាមួយផ្នែកឯកជន នាថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១០
- យោងលិខិតលេខ ៧២៣៥ កសក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អនុលោមតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ១:** បង្កើតអនុក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម ផ្នែករាជរដ្ឋាភិបាល ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម គិត សេង | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សហប្រធាន |
| ២- ឯកឧត្តម វង់ សណ្តាប់ | អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សហអនុប្រធាន |
| ៣- ឯកឧត្តម ហ៊ី បាវី | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានអគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ | សមាជិក |
| ៤- លោក អ៊ិន ប៊ុនថា | អគ្គនាយករងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៥- លោក ស៊ុំ ណារុន | អគ្គនាយករងនៃអគ្គនាយកដ្ឋានកាំកុងត្រូល | សមាជិក |
| ៦- អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ភានុវត្តី | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៧- លោក ថៃ ឫទ្ធី | នាយករងអាជីវកម្មកំពង់ផែស្វយ័តក្រុងព្រះសីហនុ | សមាជិក |
| ៨- លោក នួន ច័ន្ទរិទ្ធ | ប្រធាននាយកដ្ឋានផែនការបច្ចេកទេស និងកិច្ចការអន្តរជាតិនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |
| ៩- លោក ឌុយ ចាន់តារា | អនុប្រធាននាយកដ្ឋានដឹកជញ្ជូនផ្លូវគោកនៃក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១០-លោក នង សាវី | អនុប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ចនៃក្រសួងមហាផ្ទៃ | សមាជិក |
| ១១-លោក អ៊ុង លុយណា | ប្រធានផ្នែកស្រាវជ្រាវ និងវិភាគគោលនយោបាយ សង្គមកិច្ចនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |

**ប្រការ២:** អនុក្រុមការងារខាងលើនេះ មានភារកិច្ចដូចខាងក្រោម :

- ពិភាក្សា និងសហការជាមួយដៃគូផ្នែកឯកជន ដើម្បីសម្រេចជ្រើសរើសពូជ-បច្ចេកទេសដាំដុះ ការស្វែងរកទីផ្សារសម្រាប់ការនាំចេញកសិផល ក្នុងនោះសំខាន់គឺ**ការនាំចេញអង្ករ** ដោយយកចិត្តទុកដាក់

ចាប់តាំងពីពេលដាំដុះ ថែទាំ ប្រមូលផល ការរក្សាទុករហូតដល់ការកែច្នៃ វេចខ្ចប់ សម្រាប់បម្រើការនាំចេញអោយស្របតាមស្តង់ដារកំណត់

- សម្គាល់រាល់បញ្ហាប្រឈមក្នុងការប្រមូលស្រូវ ការកែច្នៃ និងការនាំចេញអង្ករ និងលើកឡើងនូវដំណោះស្រាយនៃបញ្ហាទាំងនោះ
- ធ្វើរបាយការណ៍លទ្ធផលការងារ និង លើកយោបល់ជូនសហប្រធានក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម ពិនិត្យ និងសម្រេច
- បំពេញការងារដទៃទៀត ដែលសហប្រធានក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម បានប្រគល់ជូន។

**ប្រការ៣:** ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង គ្រប់អភិបាលរាជធានី/ខេត្ត គ្រប់ប្រធានស្ថាប័ន/អង្គភាពដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៧ ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ប្រធាន "ក.អ.ក"
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៦០ សហវ

# សារាចរណែនាំ
## ស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា
## រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០១២

យោងសារាចរណែនាំលេខ ០៨ សរណន ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ ។

យោងប្រកាសលេខ ៧៤០ សហវ.ហម.ប្រក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១០ ស្តីពីការបង្កើតថវិកាផ្នែកសម្រាប់ក្រុង ស្រុក ខណ្ឌ ដែលមានរចនាសម្ព័ន្ធការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិកា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០១២ ដូចខាងក្រោម ៖

## I. ការរៀបចំចំណូលថវិកា

1. ចំណូលចរន្តថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានគិតគូរលើមូលដ្ឋានប្រភពចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ដែលបានកំណត់ដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គម្រោងចំណូលថវិកានេះត្រូវបានរៀបចំដូចតទៅ ៖

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ៖
  + លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  + ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  + ប៉ាន់ស្មានលើការរីកចម្រើនសេដ្ឋកិច្ចនៅពេលខាងមុខ
  + ការប្រែប្រួលដែលអាចកើតមានឡើងដោយអត្រា និងចំនួនមូលដ្ឋានប្រមូលពន្ធ
  + ចំណូលដែលសង្ឃឹមថា បានមកពីការបង្កើតពន្ធថ្មី
  + ដូចជាពន្ធលើអចលនទ្រព្យ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងក្នុងមាតិកាថវិកា អនុគណនី ៧០៧១ ពន្ធលើអចលនទ្រព្យរូបវន្តបុគ្គល និងអនុគណនី៧០៧២ ពន្ធលើអចលនទ្រព្យនីតិបុគ្គល។
- ទន្ទឹមនឹងនេះ ចំណូលមិនមែនសារពើពន្ធត្រូវបានគិតគូរទៅតាមកិច្ចការដែលនាំឲ្យមានផលទុន ដូចជា កិច្ចសន្យាជួល សេវាកម្ម និងកែលំអអគារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋព្រមទាំងប្រមូលបំណុលដែលត្រូវទារជាដើម ។ ចំណូលទាំងអស់នេះត្រូវផ្អែកលើមូលដ្ឋានតួលេខស្ថិតិសម្រេចបាននៃឆ្នាំកន្លងមក និងការរីកចម្រើននៃសេដ្ឋកិច្ច ។

/.

ចំពោះនីតិវិធី គឺអភិបាលនៃគណៈអភិបាលរាជធានី ខេត្តត្រូវអញ្ជើញមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សាខាពន្ធដារ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរជំនាញដែលពាក់ព័ន្ធក្នុងការប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ។

2. ចំណូលផ្ទៃក្នុងជាមូលធនរបស់ថវិការាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងករណីដែលមាន គឺត្រូវយកចិត្តទុកដាក់បញ្ចូលទៅក្នុងគម្រោងចំណូលនៃជំពូក១៣ ។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់កត់ត្រាបញ្ចូលនូវចំណូលពីជំនួយមនុស្សធម៌ និងជំនួយពីបរទេសដែលសប្បុរសជនអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា បានទៅទំនាក់ទំនងផ្តល់ហិរញ្ញប្បទានផ្ទាល់ជាមួយរាជធានី ខេត្ត រួចហើយ ។ សម្រាប់ថវិការាជធានី ខេត្ត ដើម្បីមកចូលរួមពិភាក្សាគិតគូររៀបចំជាគម្រោងចំណូលទៅតាមជំពូក គណនី អនុគណនី នៃតារាងឧបសម្ព័ន្ធទី ១ ដែលជូនភ្ជាប់មកជាមួយនេះ ។

## II. ការរៀបចំចំណាយថវិកា

3. រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំនូវគម្រោងចំណាយទៅតាមជំពូក គណនី អនុគណនី សម្រាប់រាល់សកម្មភាពសេវាទាំងអស់ដោយកាត់បន្ថយមុខចំណាយណាដែលពុំចាំបាច់ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ។ របៀបគិតគូរនូវតម្រូវការនានា គឺជាការកំណត់នូវមុខចំណាយនីមួយៗឲ្យច្បាស់លាស់ និងដោយផ្អែកលើកត្តានានាដែលទាក់ទងផ្ទាល់ទៅនឹងមុខចំណាយនោះដូចជា តារាងបុគ្គលិក បញ្ជីប៉ាន់ស្មានបរិមាណ តំលៃ សម្ភារៈ ឬសេវា.....។ ចំពោះសម្ភារៈបរិក្ខាដែលប្រើប្រាស់ជាប្រចាំត្រូវគិតគូរដោយផ្អែកតាមតួលេខស្ថិតិគណនេយ្យថវិកាជាមធ្យមភាគនៃបណ្តាឆ្នាំកន្លងមក ។ ចំណែកសោហ៊ុយធ្វើដំណើរ ស្នាក់នៅ បេសកកម្មត្រូវផ្អែកលើរបបកំណត់ជាធរមាន (អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការកំណត់ប្រាក់របបបេសកកម្មក្នុង និងក្រៅប្រទេស) ។

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំគម្រោងចំណាយថវិកាទៅតាមគំរូតារាងឧបសម្ព័ន្ធទី២ «ក» និង«ខ»ទន្ទឹមនោះត្រូវបំពេញតារាងលំអិតចំណាយតាមជំពូកនីមួយៗ (ចំនួន៧តារាង) ដែលភ្ជាប់ជាមួយនឹងសារាចរណែនាំនេះ ។

4. ចំណាយទាំងអស់ត្រូវតែមានការវិភាគ និងមានលិខិតយុត្តិការភ្ជាប់មកជាមួយតាមជំពូក គណនី អនុគណនី ដើម្បីបង្ហាញឲ្យឃើញថា ការគិតគូរចំណាយរបស់ខ្លួនមានភាពត្រឹមត្រូវហ្មត់ចត់ និងសមហេតុផល។ លិខិតយុត្តិការទាំងអស់នេះនឹងធ្វើជាមូលដ្ឋាននៃការពិនិត្យពិភាក្សាថវិកា ។

### II.1. ការរៀបចំគម្រោងចំណាយចរន្ត

5. លិខិតយុត្តិការនៃចំណាយចរន្តមានគោលដៅសំខាន់ៗដូចតទៅ ៖

### ប្រភេទ ១ : មធ្យោបាយសេវា
### ជំពូក ៦២ និង ៦៤ សេវាខាងក្រៅផ្សេងៗ និងបន្ទុកបុគ្គលិក

6. ចំណាយសម្រាប់បុគ្គលិកត្រូវតែគិតគូរឲ្យបានច្បាស់លាស់ ។ ចំណាយលើជំពូក ៦៤ ត្រូវបានចាត់ទុកជាចំណាយដែលមានអាទិភាពបំផុតក្នុងការរៀបចំគម្រោងថវិកា ។ ចំណាយបន្ទុកបុគ្គលិកត្រូវគ្រោងដោយបង្កើន ២០% លើបៀវត្សមូលដ្ឋាននៃតារាងប្រាក់បៀវត្សដែលចេញដោយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលក្នុងឆ្នាំ ២០១១ ។ ចំពោះចំនួនមន្ត្រីរាជការបន្ថែមថ្មីត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល

តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណៈភាពត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន ។

ចំពោះគម្រោងប្រាក់ឧបត្ថម្ភរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងនៅក្នុងជំពូក ៦៤ គណនី ៦៤៤ អនុគណនី ៦៤៤២ «លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខណ្ឌ» តាមការកំណត់ប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងអនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ។

ក្នុងករណីដែលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតម្រូវការអំពីពលករអណ្តែត មន្ត្រីជាប់កិច្ចសន្យាសម្រាប់ការងារឯកទេសដែលត្រូវចុះកិច្ចសន្យាអនុវត្តសម្រាប់រយៈពេលខ្លីជាកំណត់ត្រូវគ្រោងនៅក្នុងជំពូក៦២ គណនី ៦២១ និងអនុគណនី ៦២១១ ។

7. ចំនួនបុគ្គលិកទាំងអស់ ដែលស្ថិតនៅក្រោមឱវាទរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបូកសរុបនៅក្នុងតារាង ៥«ក» និង ចំនួនក្រុមប្រឹក្សាទាំងអស់ត្រូវបូកសរុបនៅក្នុងតារាង ៥«ខ» ដែលបានភ្ជាប់ជូនមកជាមួយនេះ ។ សលាកប័ត្រនេះមានចែកជាច្រើនខ្ទង់ សម្រាប់កត់ត្រានូវប្រភេទបុគ្គលិកទាំងអស់ដែលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាន ។

8. បុគ្គលិក មន្ត្រីរាជការ ដែលលំអិតទៅតាមអង្គភាពនីមួយៗហើយ ចំនួននេះត្រូវតែផ្ទៀងផ្ទាត់ជាមួយនឹងចំនួនដែលមាននៅក្នុងតារាងសរុបចំណាយ (តាមតារាងប្រព័ន្ធប្រាក់បៀវត្សរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល)។

9. រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវលម្អិតចំនួនបុគ្គលិកទៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នីមួយៗដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន ។

## ជំពូក ៦០ និង ៦១ ការទិញ និងសេវាខាងក្រៅ

10. ជំពូក ៦០ និង ៦១ ប្រមូលផ្តុំរាល់ការចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ជួសជុលតូច និងចំណាយជាគុណប្រយោជន៍របស់រាជធានី ខេត្ត ។ ឥណទានចំណាយក្នុងជំពូកនេះ ចែកចេញជាពីរផ្នែកសំខាន់ៗ ៖

មួយផ្នែកជាឥណទានសម្រាប់បំរើឲ្យកិច្ចប្រតិបត្តិការរដ្ឋបាលសុទ្ធសាធ ដែលចាំបាច់ត្រូវគិតគូរឲ្យបានហ្មត់ចត់ និងត្បិតត្បៀតសន្សំសំចៃដោយផ្អែកលើគោលការណ៍រួមរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងចំណាយសាធារណៈ ។ ក្នុងឆ្នាំ ២០១២ ឥណទានចំណាយផ្នែកនេះ គឺអនុញ្ញាតឲ្យគ្រោងក្នុងកម្រិតប្រហាក់ប្រហែលនឹងឆ្នាំ២០១១ តែប៉ុណ្ណោះ ។ ដោយឡែកថ្លៃឈ្នួល និងបន្ទុក (គណនី ៦១៣) គឺអនុញ្ញាតឲ្យគ្រោងតែចំណាយសម្រាប់ជួលស្នាក់ការរដ្ឋបាលតែប៉ុណ្ណោះ ។

មួយផ្នែកទៀតជាឥណទានសម្រាប់បំរើដល់គុណប្រយោជន៍របស់រាជធានី ខេត្តក្នុងការរៀបចំមូលដ្ឋានសម្ភារៈនៃសេវាសាធារណៈ និងការអភិវឌ្ឍរបស់រាជធានី ខេត្ត ។ ផ្អែកលើផែនការអភិវឌ្ឍរាជធានី ខេត្ត របស់ក្រសួងមហាផ្ទៃ រាជធានី ខេត្ត នីមួយៗចាំបាច់ត្រូវរៀបចំទៅតាមលំដាប់លំដោយនៃអាទិភាពរបស់គម្រោងចំណាយនីមួយៗ អំពីការងារជាគុណប្រយោជន៍របស់រាជធានី ខេត្ត ដើម្បីដាក់គម្រោងនេះឆ្លងការពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ក្នុងពេលធ្វើការពិភាក្សាគម្រោងថវិកាប្រចាំឆ្នាំ ។ ទន្ទឹមនោះ រាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់បង្កើននូវចំណាយផ្នែកនេះ ក្នុងករណីដែលលទ្ធភាពចំណូលសម្រេចបានលើសផែនការ ព្រោះការអភិវឌ្ឍរាជធានី ខេត្ត គឺជាគោលបំណងនៃគោលនយោបាយ និងជាទិសដៅយុទ្ធសាស្ត្រអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

11. អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវគ្រោងឥណទានសម្រាប់ចំណាយជាគុណប្រយោជន៍រាជធានី ខេត្ត តាមការងារនីមួយៗ (បំភ្លឺសាធារណៈ ប្រមូលសំរាម អនាម័យ សន្តិសុខ ប្រឆាំងអគ្គិភ័យ ការផ្គត់ផ្គង់ទឹក...) និងតាមការដ្ឋាននីមួយៗ (ផ្លូវថ្នល់ ស្ពាន សួនច្បារ លូទឹក ប្រឡាយ....) ដោយមានបញ្ជាក់អំពីបញ្ជីប៉ាន់តម្លៃ និងទីតាំងច្បាស់លាស់ដែលជាឯកសារសម្រាប់ការពិភាក្សាថវិកាប្រចាំឆ្នាំ ។

12. ជាទូទៅចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ការថែទាំ និងការជួសជុលតូច ត្រូវគិតគូរទៅតាមតម្រូវការនៃកម្មវិធីសកម្មភាពឬទៅតាមបទដ្ឋានសមស្រប ។ ម្យ៉ាងទៀតរាជធានី ខេត្ត មិនត្រូវបំប៉ោងឥណទានដែលស្នើសុំសម្រាប់ចំណាយប្រភេទនេះទេ ។ ឥណទានសម្រាប់ចំណាយអចិន្ត្រៃយ៍ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ និងការទទួលភ្ញៀវ ត្រូវគិតគូរក្នុងកម្រិតប្រហាក់ប្រហែលនឹងឆ្នាំ ២០១១ និងត្រូវគ្រប់គ្រងយ៉ាងម៉ឺងម៉ាត់ ដើម្បីសន្សំសំចៃលើចំណាយប្រភេទនេះ ជាពិសេសឥណទានសម្រាប់ចំណាយអគ្គិសនី ទឹក រាជធានី ខេត្ត ត្រូវគ្រោងឲ្យបានគ្រប់គ្រាន់សម្រាប់តម្រូវការក្នុងឆ្នាំ និងការសងបំណុល ។ ក្នុងករណីដែលរាជធានី ខេត្ត គ្រោងមិនបានគ្រប់គ្រាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងធ្វើនិយ័តភាពឥណទានផ្ទៃក្នុងជំពូកថវិការបស់រាជធានី ខេត្ត ហើយដាក់កម្មវិធីចំណាយសម្រាប់ទូទាត់ជូនរាជធានី ខេត្ត ដោយស្វ័យប្រវត្តិ ។

## ប្រភេទ ៣ : ចំណាយអន្តរាគមន៍សាធារណៈ
## ជំពូក ៦៥ : ការឧបត្ថម្ភធន និងជំនួយសង្គម

13. ចំណាយប្រភេទនេះត្រូវថែងលំអិតឲ្យបានច្បាស់លាស់ នូវគោលដៅដែលត្រូវសម្រេច ។ ត្រូវពិនិត្យជ្រើសរើសចំណាយប្រភេទនេះឲ្យបានហ្មត់ចត់ ដោយផ្អែកលើលក្ខណៈសម្បត្តិនៃអ្នកដែលទទួលផលនិងចំនួនទឹកប្រាក់ ដែលត្រូវពិនិត្យផ្តល់ជូន ។

## ប្រភេទ ៤ : ចំណាយផ្សេងៗ
## ជំពូក ៦៣ : ពន្ធ និងអាករ

14. ចំណាយប្រភេទនេះ គឺសម្រាប់កាតព្វកិច្ចពន្ធ ដូចចំណាយលើអាករ (លតាប័ត្រ....) ពន្ធប្រថាប់ត្រាសម្រាប់ទទួលកម្មសិទ្ធិ និងចំណាយបង់ពន្ធអាករផ្សេងៗទៀតតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ប្រភេទ ៦ : ចំណាយមិនបានគ្រោងទុក
## ជំពូក ០៩ : ចំណាយមិនបានគ្រោងទុក

15. ចំណាយប្រភេទនេះ គឺជាការគិតគូរគ្រោងបំរុងសម្រាប់ចំណាយថៃដន្យ ដែលអាចកើតមានជាយថាហេតុ នៅក្នុងឆ្នាំអនុវត្ត ។ សម្រាប់ឆ្នាំថវិកា ២០១២ ប្រភេទឥណទាននេះ គឺអនុញ្ញាតអោយគ្រោងចំនួន ៣ទៅ៥ភាគរយ ហើយខ្ទង់ចំណាយនេះពេលអនុវត្តត្រូវស្នើសុំធ្វើនិយ័តភាពទៅបំពេញឲ្យជំពូកដទៃទៀត ដែលតម្រូវការចំណាយថៃដន្យកើតមានឡើងជាយថាហេតុ និងតម្រូវការចំណាយសម្រាប់អភិវឌ្ឍន៍រាជធានី ខេត្ត ។

## II.2. ចំណាយជាមូលធន :

### ប្រភេទ ២ : អចលកម្ម
### ជំពូក២០ និងជំពូក២១: អចលកម្មអរូបី និងអចលកម្មរូបី

16. ចំណាយជាមូលធន គឺជាចំណាយសម្រាប់ធ្វើហិរញ្ញប្បទានចំពោះគម្រោងវិនិយោគ ដែលមានការព្រមព្រៀងគ្នាជាមុន និងសំដៅធ្វើឲ្យសម្រេចតាមគោលដៅដែលបានដាក់ចេញ ។

17. គម្រោងវិនិយោគរបស់រាជធានី ខេត្ត ដែលអាចគ្រោងបានក្នុងករណីដែលរាជធានី ខេត្ត បានទទួលគោលការណ៍អនុញ្ញាតជាផ្លូវការឲ្យគ្រប់គ្រងហិរញ្ញប្បទានដោយផ្ទាល់ ។

- ការវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសដោយថវិការាជធានី ខេត្ត អាចគ្រោងបានក្នុងករណីដែលរាជធានី ខេត្ត មានអតិរេកចរន្ត ឬ មានចំណូលជាមូលធនផ្ទៃក្នុងរាជធានី ខេត្ត ផ្ទាល់ ។

- ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ត្រូវផ្អែកលើកម្មវិធីជំនួយ ឬគម្រោងការដែលអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ឬ ម្ចាស់ជំនួយទ្វេភាគីបានទៅទំនាក់ទំនងផ្ទាល់ជាមួយរាជធានី ខេត្ត ដើម្បីកត់ត្រាចូលទៅក្នុងគម្រោងថវិការបស់រាជធានី ខេត្ត ។ ចំពោះហិរញ្ញប្បទានពីខាងក្រៅដែលបានធ្វើហិរញ្ញប្បទានទៅក្នុងមូលនិធិក្រុង ស្រុក ខេត្តសាមីត្រូវគ្រោង និងផ្តល់ព័ត៌មានដល់រដ្ឋបាលក្រុង ស្រុក ដើម្បីត្រៀមលក្ខណៈទទួលប្រតិភូកម្មក្នុងការអនុវត្ត ។ ទន្ទឹមនឹងនេះ ក៏ត្រូវយកចិត្តទុកដាក់ផងដែរ ក្នុងការកត់ត្រារាល់ចំណាយថវិកាបដិភាគជាប្រាក់រៀលដែលត្រូវអនុវត្តជាមួយគម្រោងដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ ។

18. ចំណាយនេះជាចំណាយកសាងថ្មីដែលមានទំហំទឹកប្រាក់ច្រើន ដូចជា ការរៀបចំកែលំអដីធ្លី ការរៀបចំកែលំអអគារ សំណង់អគារហេដ្ឋារចនាសម្ព័ន្ធ បណ្តាញបង្ហូរទឹក ផ្លូវថ្នល់ ជាពសាស្ត្រ ស្ពាន និងសំណង់ផ្សេងៗទៀត ។

## III. សរុបគម្រោងចំណូល ចំណាយ :

19. ឆ្នាំ ២០១២ គឺជាឆ្នាំទី ៤ របស់រាជរដ្ឋាភិបាលអណត្តិទី ៤ រាជរដ្ឋាភិបាលបានព្យាករណ៍នូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់៦.៥ភាគរយ និងអត្រាអតិផរណាក្នុងរង្វង់៥ភាគរយ ហើយបន្តរក្សាបាននូវស្ថេរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ចនៅតែជាមូលដ្ឋានគន្លឹះ និងចាំបាច់បំផុតក្នុងការឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ **ការកាត់បន្ថយភាពក្រីក្រ ភាពសុខដុមរមនា និងសុភមង្គល របស់ប្រជាជន។**

ផ្អែកលើមូលដ្ឋាននៃ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣** ពិសេស ដើម្បីបម្រើឲ្យការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយអភិវឌ្ឍតាមវិស័យ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ ២០១២ មានគោលដៅសំខាន់ៗ ដូចតទៅ ៖

- ធានាឲ្យបាននូវការអនុវត្តគោលបំណង គោលនយោបាយ និងកម្មវិធីឬ/និងយុទ្ធសាស្ត្រអាទិភាពតាមវិស័យនៅក្នុងក្របខ័ណ្ឌនៃការអនុវត្ត **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** តាមរយៈ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣** ។
- ធានាការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ជាពិសេស ការអភិវឌ្ឍវិស័យអាទិភាព រួមមានវិស័យសេដ្ឋកិច្ច សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអភិវឌ្ឍវិស័យឯកជន ដើម្បីរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ជំរុញកំណើន និងចីរភាពកំណើន។
- ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈ ៣ ឆ្នាំ រំកិល (២០១២-២០១៤)។

- ជានាបម្រើឲ្យការបន្តសកម្មភាពកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលលើគ្រប់ផ្នែក ដែលរួមមាន កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ កំណែទម្រង់វិស័យកងទ័ព និងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដើម្បីពង្រឹងអភិបាលកិច្ចល្អ និងបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។
- ជានាបន្តផ្តល់អាទិភាពដល់បណ្តាវិស័យ ការដ្ឋាននិងសកម្មភាពការងារសំខាន់ៗ រួមមាន ៖
  - **ការបង្កើន និងលើកកំពស់គុណភាពសេវាកម្មនៅក្នុងវិស័យសង្គមកិច្ច** ជាពិសេស វិស័យអប់រំ សុខាភិបាល ការកសាងធនធានមនុស្ស និងសុវត្ថិភាពសង្គម ។
  - **ការបង្កើន និងលើកកំពស់សកម្មភាពដែលបម្រើវិស័យសេដ្ឋកិច្ច** ជាពិសេស វិស័យកសិកម្ម ធារាសាស្ត្រ ការអភិវឌ្ឍជនបទ កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ។
  - **ការងារការពារអធិបតេយ្យភាព និងបូរណភាពទឹកដី ព្រមទាំងការបោះឆ្នោតព្រឹទ្ធសភា និងការបោះឆ្នោតឃុំ-សង្កាត់** ដើម្បីជានាប្រក្រតីភាពនៃដំណើរការប្រជាធិបតេយ្យការូបនីយកម្មថ្នាក់មូលដ្ឋាននៅកម្ពុជា ។

គម្រោងចំណូល ចំណាយថវិការបស់រាជធានី ខេត្ត នីមួយៗដែលបានគិតគូរ រួមមានទាំងការជានាចំណាយដែលមិនទាន់បានធ្វើការទូទាត់ និងចំណូលដែលមិនទាន់បានប្រមូលអស់នៃការគ្រប់គ្រងក្នុងឆ្នាំមុនៗ ។ គម្រោងចំណូល ចំណាយនេះត្រូវរៀបចំអោយមានតុល្យភាពពិតប្រាកដ ដើម្បីរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ។

20. ចំពោះគម្រោងចំណូល ចំណាយរាជធានី ខេត្ត ត្រូវភ្ជាប់មកជាមួយនូវគម្រោងបែងចែកលំអិតតាមក្រុង ស្រុក ខណ្ឌនីមួយៗ ដូចដែលមានគំរូតារាងឧបសម្ព័ន្ធ២ « ខ » ដែលភ្ជាប់នឹងសារាចរណែនាំនេះ ។

21. ដោយឡែកនៅឆ្នាំ ២០១២ ខាងមុខនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសពង្រឹងនូវគោលដៅជំហានទី១ គឺភាពជឿទុកចិត្តបាននៃថវិកា តាមរយៈការបន្តជំរុញការកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបង្កើនភាពគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា ដើម្បីជានាឲ្យការបើកផ្តល់ថវិកាបានទាន់ពេលវេលា ។ ពង្រឹងការកសាងក្របខ័ណ្ឌគោលនយោបាយចំណូល ដើម្បីរក្សាស្ថេរភាពចំណូលប្រកបដោយនិរន្តរភាព និងការអនុវត្តគោលដៅជំហានទី២ ។ ទន្ទឹមនឹងនេះ បន្តជំរុញការរៀបចំផែនការសកម្មភាព និងបន្តអនុវត្តនូវបណ្តាលសកម្មភាពការងារសម្រាប់ឈានចូលនូវគោលដៅជំហានទី៣ និង ទី៤ គឺការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ និងការពង្រឹងការឆ្លើយតបនៃថវិកាទៅនឹងគោលនយោបាយដែលរួមមាន ការបន្តពង្រឹង និងកែលំអការអនុវត្តប្លង់គណនេយ្យ និងមាតិកាថវិកាថ្មី ការបន្តពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធី និងជំរុញការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដើម្បីអោយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្មីស្តែងឡើងជាសមិទ្ធិផល និងជាកំលាំងចលករក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

22. បន្តជំរុញអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ពិសេសជានាពង្រឹងសមត្ថភាពរដ្ឋបាលបច្ចេកទេស និងហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ សម្រាប់ការអភិវឌ្ឍមូលដ្ឋាន និងពង្រីកមូលដ្ឋាន នៃការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិសហមជ្ឈការ ពិសេសគឺដើម្បីបំរើអោយគោលការណ៍ "រដ្ឋបាលឯកភាព" ដូចមានកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ក្នុងកម្មវិធីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំនិងអនុវត្តផែនការបង្កើនប្រសិទ្ធភាពនៃការផ្ទេរ និងការផ្តល់ថវិកាជូនមូលនិធិក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ រួមមានទាំងលទ្ធភាពនៃការពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារផងដែរ ។ លើសពីនេះទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងរៀបចំលិខិតបទដ្ឋាននានាដូចជា

អនុក្រឹត្យ សារាចរណែនាំសម្រាប់អនុវត្តប្រព័ន្ធហិរញ្ញវត្ថុ និងថវិការបស់រដ្ឋបាលនៅថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីឲ្យការអនុវត្តមានប្រសិទ្ធភាពខ្ពស់ ។

23. បង្កើនមូលនិធិថវិកាឃុំ សង្កាត់ ឆ្នាំ ២០១២ ស្មើនឹង២,៨០% នៃចំណូលចរន្តថវិការដ្ឋឆ្នាំ ២០១១ ដែលបានអនុម័តដោយច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១ ។

24. ចំពោះការរៀបចំគម្រោងថវិកាថ្នាក់ ក្រុង ស្រុក ខណ្ឌ គណៈអភិបាលរាជធានី ខេត្ត ទទួលខុសត្រូវក្នុងការជួយគាំទ្របច្ចេកទេសដោយមានគម្រោងថវិការបស់ខ្លួនបានត្រឹមត្រូវ ។

អភិបាលនៃគណៈអភិបាលខេត្ត ត្រូវធ្វើការបូកសរុបគម្រោងថវិការបស់រាជធានី គម្រោងថវិការបស់ខេត្ត គម្រោងថវិការបស់ក្រុង គម្រោងថវិការបស់ស្រុក គម្រោងថវិការបស់ខណ្ឌ ក្នុងរាជធានី ខេត្តរបស់ខ្លួនចូលក្នុងទម្រង់ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់ជាមួយនូវគម្រោងថវិកា និងសេចក្តីអត្ថាធិប្បាយពន្យល់របស់ខេត្ត របស់ក្រុង របស់ស្រុក ហើយត្រូវផ្ញើគម្រោង និងឯកសារទាំងនេះមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

25. ពេលទទួលបានសារាចរណែនាំ រាជធានី ខេត្ត ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល ចំណាយថវិការបស់ខ្លួនសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ ទៅតាមតារាងឧបសម្ព័ន្ធតារាងគំរូ (ឧបសម្ព័ន្ធ១ ឧបសម្ព័ន្ធ២ និងតារាងលេខ ១ ដល់លេខ ៧) ដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន) ចំនួនពីរច្បាប់ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១១ ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិភាក្សាកម្រិតជំនាញ និងបូកសរុបសម្រាប់ពិភាក្សាចាប់ពីថ្ងៃទី ០១ ដល់ ៣១ ខែ សីហា ឆ្នាំ២០១១ ។ តួលេខគម្រោងចំណូល ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1.2.3) ហើយឯកត្តាទាបបំផុតគិតត្រឹម 0.1 លានរៀល ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សង្ឃឹមជឿជាក់យ៉ាងមុតមាំថា អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ទាំងអស់នឹងខិតខំយកចិត្តទុកដាក់ចាត់ចែងអនុវត្តតាមខ្លឹមសារនៃសារាចរនេះ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត់ ឈន់**

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- (ដើម្បីជូនជ្រាប)
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- (ដើម្បីមុខការ)
- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត ...........

**ការគ្រប់គ្រងឆ្នាំ ២០១២**

ឧបសម្ព័ន្ធទី ១

**តារាងសរុបចំណូលថវិការបស់រាជធានី ខេត្ត**

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | តារាងរាយមុខចំណូល (តាមមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០១១ | | | គម្រោងឆ្នាំ២០១២ |
|---|---|---|---|---|---|---|---|
| | | | | ច្បាប់ដើមឆ្នាំ | អនុវត្តឆមាសទី១ | ប៉ាន់ស្មានឆ្នាំ | |
| | | | | | | | |

ថ្ងៃទី.......... ខែ.............. ឆ្នាំ ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី.......... ខែ................ ឆ្នាំ ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**

**សេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ថ្ងៃទី.......... ខែ.............. ឆ្នាំ ២០១១

**ហត្ថលេខា និង ត្រាអភិបាល**

**នៃគណៈអភិបាលរាជធានី ខេត្ត**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត

ការគ្រប់គ្រងឆ្នាំ ២០១២ ឧបសម្ព័ន្ធ ២-ក

## តារាងសរុបចំណាយថវិការបស់រាជធានី ខេត្ត

ឯកតា: ពាន់រៀល

| ជំពូក | គណនី | អនុគណនី | ការរាយមុខចំណាយ (តាមមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០១១ | | | គម្រោងឆ្នាំ ២០១២ | |
|---|---|---|---|---|---|---|---|---|
| | | | | ច្បាប់ដើមឆ្នាំ | អនុវត្តឆមាសទី១ | ប៉ាន់ស្មានឆ្នាំ | រាជធានី ខេត្ត | ក្រុង ស្រុក... |
| | | | | | | | | |

ថ្ងៃទី........ខែ..........ឆ្នាំ ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី........ខែ ..............ឆ្នាំ ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**
**សេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ថ្ងៃទី........ខែ ..........ឆ្នាំ ២០១១

**ហត្ថលេខា និង ត្រាអភិបាល**
**នៃគណៈអភិបាលរាជធានី ខេត្ត**

រាជធានី ខេត្ត............

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ឧបសម្ព័ន្ធទី២ "ខ"

## គម្រោងថវិកាឆ្នាំ ២០១២

## តារាងសរុបចំណាយថវិការបស់រាជធានី ខេត្ត............

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០១២ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | សរុប | សាលាខេត្ត | សរុប ក្រុង ស្រុក ខណ្ឌ | ក្រុង...... | ស្រុក..... | ស្រុក..... | ស្រុក..... | ស្រុក..... | ស្រុក..... | ស្រុក... | ស្រុក.. | ស្រុក.. |
| | | | | | | | | | | | | | | | |

ថ្ងៃទី.............ខែ...... .........ឆ្នាំ ២០១១
**អ្នកធ្វើតារាង**

ថ្ងៃទី ...........ខែ.............ឆ្នាំ ២០១១
**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**
**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ថ្ងៃទី        ខែ        ឆ្នាំ ២០១១
**បានឃើញ និង ឯកភាព**
**ហត្ថលេខា និង ត្រាអភិបាល**
**នៃគណៈអភិបាលរាជធានី ខេត្ត**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត ............

## គម្រោងថវិកាឆ្នាំ ២០១២

## គម្រោងចំណាយលើការទិញ (ជំពូក ៦០)

តារាង ១

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១១ | | | គំរោងថវិកាឆ្នាំ ២០១២ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនាឲ្យឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនាឲ្យឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |

ថ្ងៃទី ...... ខែ ...... ឆ្នាំ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី ...... ខែ ...... ឆ្នាំ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**

**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ថ្ងៃទី ...... ខែ ...... ឆ្នាំ២០១១

**បានឃើញ និង ឯកភាព**

**ហត្ថលេខា និង ត្រាអភិបាល**

**នៃគណៈអភិបាលរាជធានី ខេត្ត**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត............

## គម្រោងថវិកាឆ្នាំ ២០១២ គម្រោងចំណាយលើសេវាខាងក្រៅ

## ( ជំពូក ៦១ )( គុណប្រយោជន៍រាជធានី ខេត្ត )

តារាង ២

ឯកតា. លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១១ | | | គំរោងថវិកាឆ្នាំ ២០១២ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |

ថ្ងៃទី .........ខែ.........ឆ្នាំ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី.........ខែ.........ឆ្នាំ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**

**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ថ្ងៃទី.........ខែ.........ឆ្នាំ២០១១

**បានឃើញ និង ឯកភាព**

**ហត្ថលេខា និង ត្រាអភិបាល**

**នៃគណៈអភិបាលរាជធានី ខេត្ត**

ព្រះរាជាណាចក្រកម្ពុជា

រាជធានី ខេត្ត............ ជាតិ សាសនា ព្រះមហាក្សត្រ

# គម្រោងថវិកាឆ្នាំ ២០១២

## គម្រោងចំណាយលើសេវាក្រៅផ្សេងៗ (ជំពូក ៦២)

តារាង ៣

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១១ | | | គំរោងថវិកាឆ្នាំ ២០១២ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |

ថ្ងៃទី...... ខែ ... ឆ្នាំ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី ... ខែ............ឆ្នាំ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**

**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ថ្ងៃទី.. .........ខែ...... ...ឆ្នាំ២០១១

**បានឃើញ និង ឯកភាព**

**ហត្ថលេខា និង ត្រាអភិបាល**

**នៃគណៈអភិបាលរាជធានី ខេត្ត**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត............

# គម្រោងថវិកាឆ្នាំ ២០១២

## គម្រោងចំណាយលើពន្ធ និង អាករ (ជំពូក ៦៣)

តារាង ៤

ឯកតា: លានរៀល

| ជំពូក គណនី អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១១ | | | គំរោងថវិកាឆ្នាំ ២០១២ | | |
|---|---|---|---|---|---|---|---|---|---|
| | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

ថ្ងៃទី ...... ខែ ...... ឆ្នាំ២០១១
**អ្នកធ្វើតារាង**

ថ្ងៃទី............ខែ ......... ឆ្នាំ២០១១
**អគ្គលេខា និង គ្រាប្រធានមន្ទីរ**
**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ថ្ងៃទី ..... ខែ ..... ឆ្នាំ២០១១
**បានឃើញ និង ឯកភាព**
**អគ្គលេខា និង គ្រាអភិបាល**
**នៃគណៈអភិបាលរាជធានី ខេត្ត**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត............

# គម្រោងថវិកាឆ្នាំ ២០១២

## គម្រោងចំណាយលើបន្ទុកបុគ្គលិក ( ជំពូក ៦៤ )

តារាង ៥

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១១ | | | គំរោងថវិកាឆ្នាំ ២០១២ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |

ថ្ងៃទី .... ខែ .... ឆ្នាំ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី .... ខែ.... ....ឆ្នាំ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**

**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ថ្ងៃទី.........ខែ.... ...ឆ្នាំ២០១១

**បានឃើញ និង ឯកភាព**

**ហត្ថលេខា និង ត្រាអភិបាល**

**នៃគណៈអភិបាលរាជធានី ខេត្ត**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តារាង៥ "ក"

រាជធានី ខេត្ត...............

## ការគ្រប់គ្រងឆ្នាំ ២០១២
## តារាងសរុបនៃបុគ្គលិក បៀវត្ស និងប្រាក់បំណាច់

| អង្គភាព | បៀវត្ស | ចំនួនបុគ្គលិក | ប្រភេទបុគ្គលិកដែលមានសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ | | | | | ពលករ | មន្ត្រី |
|---|---|---|---|---|---|---|---|---|---|
| | សរុប | សរុប | បុគ្គ.អចិន្ត្រៃយ៍សរុប | ប្រភេទ«ក» | ប្រភេទ«ខ» | ប្រភេទ«គ» | ប្រភេទ«ឃ» | អណ្តែត | ជាប់កិច្ចសន្យា |
| សរុប | | | | | | | | | |
| សាលាខេត្ត | | | | | | | | | |
| ក្រុង | | | | | | | | | |
| ស្រុក ឬ ខណ្ឌ | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| ............................ | | | | | | | | | |
| ............................ | | | | | | | | | |
| ............................ | | | | | | | | | |

ថ្ងៃទី.......... ខែ................ ឆ្នាំ ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី.............. ខែ............... ឆ្នាំ ២០១១

**បានឃើញ និង ឯកភាព**
**ហត្ថលេខា និង ត្រាអភិបាល**
**នៃគណៈអភិបាលរាជធានី ខេត្ត**

ថ្ងៃទី........... ខែ................. ឆ្នាំ ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**
**សេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តារាង៥.៤.

រាជធានី ខេត្ត..............

## ការគ្រប់គ្រងឆ្នាំ ២០១២

## តារាងសរុបនៃបុគ្គលិក បៀវត្ស និងប្រាក់បំណាច់

| អង្គភាព | សរុប: | ប្រភេទក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ចំនួនប្រធានក្រុមប្រឹក្សា | | ទឹកប្រាក់ | ចំនួនសមាជិកក្រុមប្រឹក្សា | | ទឹកប្រាក់ | ផ្សេងៗ |
| សាលារាជធានី ខេត្ត | | | | | | | | |
| ក្រុង<br>ស្រុក-ខណ្ឌ | | | | | | | | |
| សរុបរួម: | | | | | | | | |

ថ្ងៃទី......... ខែ......... ឆ្នាំ ២០១១

បានឃើញ និង ឯកភាព

ហត្ថលេខា និង ត្រាអភិបាល

នៃគណៈអភិបាលរាជធានី ខេត្ត

ថ្ងៃទី......... ខែ ឆ្នាំ ២០១១

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី....... ខែ ឆ្នាំ ២០១១

អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត............

## គម្រោងថវិកាឆ្នាំ ២០១២

## គម្រោងចំណាយលើឧបត្ថម្ភធន និងជំនួយសង្គម (ជំពូក ៦៥)

តារាង ៦

ឯកតា: លានរៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា) | សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន) | | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១១ | | | គំរោងថវិកាឆ្នាំ ២០១២ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) | មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ទឹកប្រាក់ (លានរៀល) |
| | | | | | | | | | | | |

ថ្ងៃទី............ខែ.............ឆ្នាំ២០១១

**អ្នកធ្វើតារាង**

ថ្ងៃទី............ខែ.............ឆ្នាំ២០១១

**ហត្ថលេខា និង ត្រាប្រធានមន្ទីរ**

**សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ថ្ងៃទី............ខែ.............ឆ្នាំ២០១១

**បានឃើញ និង ឯកភាព**

**ហត្ថលេខា និង ត្រាអភិបាល**

**នៃគណៈអភិបាលរាជធានី ខេត្ត**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ០.១.១. . សហវ

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ កក្កដា ឆ្នាំ២០១១

# សារាចរណែនាំអនុវត្ត
## ប្រកាសលេខ ៣៨៣ សហវ.អពជ.ប្រក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១
## របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*ដើម្បីបង្កើនប្រសិទ្ធភាពទប់ស្កាត់ការប្រឈមរាល់អំពើអសកម្ម និងវិច្ឆេទកម្ម ដែលនាំដល់ការរិះគន់ពីម្ចាស់យានយន្ត និងជាពិសេសក្នុងគោលបំណងពង្រឹងអភិបាលកិច្ចនៅក្នុងអគ្គនាយកដ្ឋានពន្ធដារឱ្យកាន់តែល្អថែមទៀត ស្របតាមប្រកាសលេខ ៣៨៣ សហវ.អពជ.ប្រក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមកំណត់ណែនាំអនុវត្ត ដូចខាងក្រោម ៖*

**I- អំពីភារកិច្ចរបស់ម្ចាស់យានយន្ត ៖**

*ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិនៃច្បាប់ និងទប់ស្កាត់ការចំណាយមិនចាំបាច់ក្នុងការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១នេះ ម្ចាស់យានយន្តត្រូវបំពេញកាតព្វកិច្ច ដូចខាងក្រោម ៖*

១. *ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១ រហូតដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១ ឱ្យបានទាន់ពេលវេលា ។*

២. *ការដាក់លិខិតប្រកាស និងបង់ពន្ធ ៖*
- *ចំពោះរថយន្ត ម្ចាស់យានយន្តត្រូវសរសេរបំពេញលិខិតប្រកាសដោយខ្លួនឯង ចំនួន ០២ ច្បាប់ ដែលមានតម្លៃស្មើ ៤០០រៀល និងបង់ពន្ធតាមច្បាប់កំណត់ ដោយភ្ជាប់មកជាមួយនូវបង្កាន់ដៃបង់ពន្ធឆ្នាំ២០១០*
- *ចំពោះទោចក្រយានយន្ត និងត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រូវទិញបណ្ណបង់ពន្ធ ដោយពុំចាំបាច់បំពេញលិខិតប្រកាសឡើយ។*

៣. *ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធដោយផ្ទាល់ នៅតាមប៉ុស្តិ៍ (ទីសំចត) ឬស្នាក់ការពន្ធដារ ឬសាខាពន្ធដារ ដែលសម្រេចដោយអាជ្ញាធរដែនដីរាជធានី-ខេត្ត ដើម្បីទប់ស្កាត់ការកើតឡើងនូវតម្លៃលើស ឬទិញបណ្ណក្លែងក្លាយ ។*

៤. *ត្រូវសហការជាមួយភ្នាក់ងារពន្ធដារ ឬសមត្ថកិច្ចនានា ឬអាជ្ញាធរដែនដី ក្នុងករណីពិនិត្យឃើញមានការបង់ពន្ធលើស ឬលក់បណ្ណបង់ពន្ធក្លែងក្លាយ ។*

៥. *លោក-លោកស្រី ជាម្ចាស់យានយន្ត ឬអាជ្ញាធរដែនដី ឬអង្គការសង្គមស៊ីវិល អាចផ្តល់មតិរិះគន់ដោយត្រូវដាក់លិខិតក្នុងប្រអប់សំបុត្រនៅសាខាពន្ធដារខេត្ត ឬទីស្នាក់ការប្រមូលពន្ធ ក្នុងករណីពិនិត្យឃើញថា មានការទារពន្ធលើស ឬភាពមិនច្បាស់លាស់ ឬអំពើវិច្ឆេទកម្មផ្សេងៗ ដូចជា ៖ មានលក់បណ្ណក្លែងក្លាយ ធ្វើឱ្យមានភាពចលាចលដែលនាំឱ្យបាត់បង់ថវិកាជាតិ និងភាពអសកម្មនានា ក្នុងការប្រមូលពន្ធ ។*

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798
mef_admin@yahoo.com

**II- អំពីភារកិច្ចរបស់ភ្នាក់ងារពន្ធដារ ៖**

ភ្នាក់ងារពន្ធដារដែលមានភារកិច្ចប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ២០១១ ត្រូវអនុវត្ត ដូចខាងក្រោម ៖

១ ត្រូវស្លៀកពាក់ឯកសណ្ឋានពន្ធដារក្នុងពេលម៉ោងធ្វើការ

២ ត្រូវមានសីលធម៌ល្អ សុភាពរាបសារ និងហ្មឺងម៉ាត់ក្នុងការងារ

៣ ត្រូវគោរពពេលម៉ោងធ្វើការឱ្យបានទៀងទាត់គឺ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ និងថ្ងៃសៅរ៍ អាទិត្យ តាមសំណូមពររបស់រដ្ឋបាលរាជធានី-ខេត្ត ក្នុងករណីចាំបាច ៖

ព្រឹក ៖ ពីម៉ោង ៨:៣០ ដល់ម៉ោង ១១:៣០

រសៀល ៖ ពីម៉ោង ១៤:០០ ដល់ម៉ោង ១៦:៣០

ដោយហេតុថា ពេលព្រឹកត្រូវបើកឯកសារ និងពេលរសៀល ត្រូវទូទាត់ប្រាក់ពន្ធដែលប្រមូលបានចូលក្នុងបេឡា ។

៤ នៅតាមប៉ុស្តិ៍ (ទីសំចត) ស្នាក់ការពន្ធដារ សាខាពន្ធដារ ភ្នាក់ងារពន្ធដារត្រូវរៀបចំកន្លែងធ្វើការឱ្យបានសមរម្យ និងមានបំពាក់សំភារ ដូចតទៅ ៖

ចងផ្ទាំងក្រណាត់ទំហំ ០.៦០ម X ៤ម និងបោះពុម្ពខិតប័ណ្ណផ្សព្វផ្សាយអំពីព័ត៌មានក្នុងយុទ្ធនាការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

នៅទីតាំងប្រមូលពន្ធ ត្រូវបិទតារាងតម្លៃប្រាក់ពន្ធ តម្លៃលិខិតប្រកាស និងព័ត៌មានផ្សេងៗទៀតដែលទាក់ទិននៅនឹងការប្រមូលពន្ធ ដើម្បីឱ្យម្ចាស់យានយន្តអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់ ។

៥. ភ្នាក់ងារពន្ធដារមិនត្រូវទារ ឬទទួលប្រាក់លើសពីការលក់ឯកសារ ឬប្រាក់កម្រៃពីការសរសេរបង្កាន់ដៃបង់ពន្ធ ទោះស្ថិតក្នុងរូបភាពណាក៏ដោយ ។ ទន្ទឹមនឹងនេះ ភ្នាក់ងារពន្ធដារត្រូវត្រៀមសាច់ប្រាក់តាមប្រភេទ ដើម្បីទូទាត់ (អាប់) ជូនម្ចាស់យានយន្តដោយភាពត្រឹមត្រូវ ។

៦. នៅតាមសាខាពន្ធដារខេត្ត និងនៅទីស្នាក់ការពន្ធដារស្រុកនីមួយៗ ភ្នាក់ងារពន្ធដារត្រូវរៀបចំប្រអប់សំបុត្រមានចាក់សោ ដើម្បីទទួលព័ត៌មានផ្សេងៗជាយថាហេតុ ។ ប្រអប់សំបុត្រនេះត្រូវបើកជារៀងរាល់ថ្ងៃហើយរាយការណ៍ជូនប្រធានអង្គភាពសាមី ដើម្បីដោះស្រាយ ។

**III- កិច្ចសហការ ៖**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំណូមពរដល់អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអង្គការសង្គមស៊ីវិល ជួយសហការក្នុងការប្រមូលពន្ធនេះឱ្យមានប្រសិទ្ធភាព និងតម្លាភាព ៖

១. ជួយណែនាំពន្យល់ និងផ្សព្វផ្សាយអំពីប្រកាស សេចក្តីជូនដំណឹង សារាចរណែនាំអនុវត្តស្តីពីពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១១ ដល់ម្ចាស់យានយន្តឱ្យបានយល់ច្បាស់អំពីកាតព្វកិច្ចរបស់ខ្លួនឱ្យបានរួសរាន់ទាន់ពេលវេលា ជៀសវាងកកកុំ ប្រមូលផ្តុំមកបង់ពន្ធនៅថ្ងៃផុតកំណត់

២ រក្សានូវសមភាពភាព មិនលំអៀង ដោយគតិបណ្ឌិត និងយុត្តិធម៌

៣ ជួយពិនិត្យ តាមដាន ឃ្លាំមើល និងផ្តល់ព័ត៌មានមកអគ្គនាយកដ្ឋានពន្ធដារពីប្រភពផលិត និងប្រើប្រាស់ឯកសារក្លែងក្លាយ ដើម្បីឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសមកផ្តន្ទាទោសតាមច្បាប់ ។

អគ្គនាយកដ្ឋានពន្ធដារ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ តាមភារកិច្ចរៀងៗខ្លួន ត្រូវចាត់ចែងអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃសារាចរនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន ៖**

ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
ដើម្បីជូនជ្រាបជាព័ត៌មាន

គ្រប់សាលារាជធានី ខេត្ត

អគ្គនាយកដ្ឋានពន្ធដារ ដើម្បីអនុវត្ត

ឯកសារ-កាលប្បវត្តិ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០[illegible]

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ៣៦១ /១០ ត.រ.ក ចុះថ្ងៃទី២៣.០២.២០១០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អ៊ិនធឺណាស្សូណាល់ ផេភ័រប្រូឌឹក ម៉េញូហ្វាក់ឆរីង ចុះថ្ងៃទី ១៨.០៦.២០១១

## សម្រេច

